ទៀងផ្សេងៗ ក្នុងរជ្ជកាលព្រះបាទ នរោត្តម

រឿងផ្សេងៗ មាននៅក្នុងព្រះបរមរាជវាំងខ្មែរ ក្នុងរជ្ជកាល ព្រះបាទ នរោត្តម នៅសតវត្សទី១៩ ដែលលោកឧត្តមនាវាត្រី PAUL BRANDA ជាជនជាតិបារាំង បានសរសេរ ហើយចុះផ្សាយនៅឆ្នាំ ១៨៩២ មានចំណងជើង : ÇA ET LA – COCHINCHINE ET CAMBODGE : L'AME KHMERE។

សរសេរនៅសៃហ្គន ថ្ងៃទី៣ តុលា ឆ្នាំ ១៨៨៤ :

ហ្លួងនរោត្តម ទ្រង់បញ្ជាឱ្យហៅព្រះស្នំឯក ចូលគាល់ព្រះអង្គ។ ព្រះអង្គមានព្រះបន្ទូលថា :

- អញ ស្រឡាញ់ឯងពិតណាស់ ហើយលើសអស់ស្នំស្រីផ្លាវឯទៀតៗផង តែសេចក្តីស្នេហារបស់អញចំពោះឯង រាមានអវសាន ព្រោះសព្វថ្ងៃនេះ អញស្រឡាញ់គេម្នាក់ទៀត។ អញយល់ចិត្តឯងហើយថា ដំណឹងនេះធ្វើឱ្យឯងឈឺចិត្តណាស់ ដោយដឹងថាឯងមានកូនប្រសែង។ តែអញនឹង ធ្វើឱ្យឯង រៀរចាកនឹងទុក្ខនេះ ហើយអាចរក្សាកិត្តិយសរបស់ឯង ដែលធ្លាប់មានជាមួយអញ ក៏ អញនឹងឱ្យឯងរៀបការជាមួយនឹងសម្តេចចៅហ្វ (រដ្ឋមន្ត្រីទី១)។

ព្រះស្នំឯក លុះនាង ស្តាប់ព្រះបន្ទូលសព្វសេចក្តីហើយ ក៏តបឆ្លើយទាំងទឹកភ្នែកថា :

- ព្រះករុណា ជាអម្ចាស់ជីវិតលើកួ្ងង សូមល្អងធ្លាលីជ្រាបថា ព្រះចិន្តា ឈប់ស្នេហ៍នឹងខ្ញុំម្ចាស់ រានាំសង្វេក និង ចំបែងទ្រូងណាស់ទៅហើយ តែខ្ញុំម្ចាស់ សូមអង្វរព្រះទ័យ សូមព្រះអង្គ កុំនាំទុក្ខថ្មីបន្ថែមមកលើខ្ញុំម្ចាស់ទៀត ដោយឱ្យខ្ញុំ

ម្ចាស់ទៅរៀបការជាមួយសម្តេចចៅហ្វ៊ា ដែលវានឹងនាំឱ្យខ្ញុំម្ចាស់ បាត់បង់កិត្តិយសរបស់ខ្ញុំម្ចាស់ទៅវិញទេ។ ចំពោះខ្ញុំម្ចាស់ បើព្រះអង្គឈប់ស្រឡាញ់ខ្ញុំម្ចាស់ ខ្ញុំម្ចាស់យល់ឃើញថា ការរក្សាកិត្តិយសរបស់ខ្ញុំម្ចាស់ គឺសូមព្រះអង្គ មេត្តាប្រគល់ខ្លួនខ្ញុំម្ចាស់ ថ្វាយទៅព្រះរាជបុត្រច្បង ទើបវាសមរម្យជាងសំរាប់ខ្ញុំម្ចាស់។

- ព្រះបាទនរោត្តម មានបន្ទូលតបដោយកំហឹងថា : នែ មីថោកទាប ដូចគេនិយាយប្រាប់អញមែន ថាហង១ងជិតអញ ដូច្នេះបើហង១ង ចង់រក្សាកិត្តិយស ដូចហង១ងចង់បានមែន, អ្នកម្នាងអើយ ! អញនឹងផ្តល់ឱ្យហង១ងបានដូចសេចក្តីបំណង គឺ រំពាត់ផ្តៅ។

មានបន្ទូលរួចហើយ ហ្លួងនរោត្តម ទ្រង់បញ្ជាឱ្យអាមាត្រ វាយខ្នងស្ទុំ១ងនោះ នឹងរំពាត់ផ្តៅ រហូតដល់ជិតស្លាប់។ បន្ទាប់មកព្រះអង្គ ក៏ឱ្យអាមាត្រ ទៅអញ្ជើញព្រះរាជបុត្រច្បងរបស់ព្រះអង្គ ឱ្យចូលគាល់ទ្រង់។ ពេលព្រះរាជបុត្រមកដល់ភ្លាម ព្រះអង្គក៏ដោះអាវសូត្ររបស់ព្រះអង្គបង្ហាញ សំណាមរបួសនៅលើខ្នងព្រះអង្គ ដែលព្រះអង្គ បានទទួលទណ្ឌកម្មពីព្រះបិតា កាលទ្រង់នៅជាយុវជន រួចទ្រង់មានព្រះរាជឱង្ការថា :

- នេះជាស្នាមកំហុសរបស់អញចំពោះព្រះបិតាអញ ដូច្នេះ ១ង ដែលធ្វើកំហុស ចំពោះអញ ដែលជាបិតា១ង ត្រូវតែ ១ង ទទួលទណ្ឌកម្មដូចអញនោះដែរ។

ទឿងផ្សេងៗ ក្នុងរជ្ជកាលព្រះបាទ នរោត្តម

ត្រូវដឹងថា តាមព្រះរាជប្រពៃណី បើព្រះរាជបុត្រណា ធ្លាប់ទទួលទណ្ឌកម្ម រាយនឹងរំពាត់ផ្តៅ ព្រះអង្គនោះ មិនអាចឡើងគ្រងរាជសម្បត្តិបាននោះឡើយ។ តែដោយសារ បារាំងនៅជំនាន់នោះ គេធ្វើអន្តរាគមន៍ ក្រាប់បែបយ៉ាង ដើម្បីឱ្យហ្លួងនរោត្តម អាចឡើងគ្រងរាជ្យបន្តពីព្រះបិតារបស់ព្រះអង្គបាន។

ព្រះរាជបុត្រ គ្រាន់តែឮសំដីព្រះបិតាភ្លាម ទ្រង់មិនចាំបាច់បន្តស្តាប់តទៅទៀត ទ្រង់ក៏ប្រញាប់ប្រញាលរត់ចេញពីបន្ទប់សវនាការ ទៅសូមឱ្យអាជ្ញាធរបារាំងជួយការពារព្រះអង្គ។ បារាំង ក៏បានស្នើរ ដល់ហ្លួងនរោត្តម ឱ្យបន្ទូរបន្ថយទោសដល់ព្រះរាជបុត្រ។ ព្រះបាទនរោត្តម ទ្រង់សុខចិត្តបន្ថយទោសនៅត្រឹមតែឃុំឃាំងនៅក្នុងព្រះរាជវាំង តែដាក់ខ្នោះឃ្នាងពី ក រហូតដល់ជើង។ ដឹងដំណឹងនេះភ្លាម ព្រះរាជបុត្រ រអ៊ូប្រាប់បារាំងថា « តើព្រះបិតា មានប្រាប់ពួកអស់លោកថា ព្រះអង្គ ឃុំឃាំងខ្ញុំក្នុងរយៈពេលប៉ុន្មានថ្ងៃដែរឬទេ... »។

ដំណឹងនេះ នាំឱ្យព្រះរាជបុត្រជាប្អូន និយាយខ្សឹមៗដោយបារម្ភថា « ព្រះអង្គ ក៏ស្ថិតនៅក្នុងករណីដូចព្រះជេដ្ឋាដែរ »។ រីឯ ព្រះរាជបុត្រទីបី មានបន្ទូលតបថា « ខ្ញុំវិញ គ្មានការព្រួយបារម្ភនោះទេ ព្រោះខ្ញុំលួចរួមរក្ស តែជាមួយព្រះក្សត្រីជាព្រះអានុជតែប៉ុណ្ណោះ »។

នៅមាន ត